ការស្វែងយល់អំពីជីវិត

# ហេតុអ្វីមនុស្ស
# មានការឈឺចាប់
# នៅលើផែនដីនេះ?





# ហេតុអ្វី មនុស្សមានការឈឺចាប់ នៅលើផែនដីនេះ?

**ជាញឹកញាប់** ពេលយើងមើលពត៌មានអន្តរជាតិ នៅលើកញ្ចក់ទូរទស្សន៍ យើងឃើញគេផ្សាយ អំពីគ្រោះទុរ្ភិក្ស និងភាពអត់ឃ្លាន នៅប្រទេសក្រីក្រ។ កម្មវិធីវិទ្យុក៏បានផ្សាយ អំពីជម្លោះអន្តរជាតិ ដែលហៀបនឹងផ្ទុះឡើងជាដើម។ កាសែតក្នុងស្រុកក៏បានជូនដំណឹងដ៏ក្រៀមក្រំ អំពីមនុស្សដែលកំពុងភ័យខ្លាចអំពើហិង្សា និងការរំលោភសិទ្ធិមនុស្ស។ យើងក៏បានឮអ្នកជិតខាងរបស់យើងនិយាយគ្នា អំពីមិត្តភក្តិរបស់ពួកគេ ដែលបានបរាជ័យ នៅក្នុងការព្យាបាលជំងឺមហារីករបស់ខ្លួន។ ការឈឺចាប់ហាក់ដូចជាកើតមាននៅគ្រប់ទីកន្លែង ហើយវាបង្កឲ្យមានសេចក្តីទុក្ខ និងសំណួរជាច្រើន។

ខ្លួនយើងផ្ទាល់ក៏អាចមានចម្ងល់ថា ហេតុអ្វីការអាក្រក់កើតឡើងចំពោះមនុស្សល្អ ហើយហេតុអ្វីការល្អ បែរជាកើតឡើងចំពោះមនុស្សអាក្រក់ទៅវិញ។ យ៉ាងណាមិញ មនុស្សជាច្រើនអាចទទួលស្គាល់ថា វាជារឿងសមហេតុផល ដែលពួកភេរវជនធ្វើឲ្យខ្លួនឯងស្លាប់ ដោយសារគ្រាប់បែកអត្តឃាត។ អ្នកបើកបរដែលមិនប្រុងប្រយ័ត្ន នឹងនាំឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរមកលើខ្លួនឯង។ ហើយអ្នកណាដែលលេងភ្លើង នោះក៏ច្រើនតែរលាកភ្លើង។ ហើយវារិតតែសមហេតុផល ដែលអ្នកជក់បារីមិនព្រមឈប់ នឹងកើតជំងឺមហារីកសួត។

ប៉ុន្តែ ចុះចំណែកឯមនុស្សស្លូតត្រង់ទាំងប្រុសស្រី ព្រមទាំងក្មេងៗផង ដែលបានស្លាប់ ដោយសារគ្រាប់បែកអត្តឃាតរបស់ភេរវករនោះ? ចុះចំណែកឯជនរងគ្រោះវ័យក្មេងម្នាក់ ដែលបានគ្រោះថ្នាក់ធ្ងន់ធ្ងរ ដល់ខួរក្បាល ដោយសារតែអ្នកបើកបរក្នុងស្ថានភាពស្រវឹងស្រា

ដែលបានបើកបុកគាត់? ចុះចំណែកឯម្ចាស់ផ្ទះដែលបានឆេះ ដោយសារអ្នកលេងភ្លើងនោះ? ហើយចុះចំណែកឯក្មេងអាយុ២ឆ្នាំ ដែលមានជំងឺមហារីកគ្រាប់ឈាម?

យើងប្រហែលមិនអាចដឹង អំពីមូលហេតុដែលនរណាម្នាក់មានជំងឺនោះទេ ប៉ុន្តែ យើងអាចដឹងខ្លះៗថា ហេតុអ្វីជំងឺកើតមាន នៅលើផែនដីនេះ។ យើងប្រហែលមិនដឹងថា ហេតុអ្វីយើងជួបប្រទះបញ្ហាណាមួយទេ តែយើងអាចដឹងអំពីរបៀបដោះស្រាយបញ្ហានោះ និងដឹងអំពីរបៀបឆ្លើយតប ឲ្យបានត្រឹមត្រូវ។

## ពិភពលោកនៃការឈឺចាប់

សូមយើងស្រមៃ អំពីពិភពលោកមួយ ដែលគ្មានការឈឺចាប់។ តើវានឹងមានលក្ខណៈដូចម្តេច? ពីដំបូង យើងស្តាប់មើលទៅ ដូចជាគួរឲ្យចាប់អារម្មណ៍ណាស់។ នៅពិភពលោកនោះ លែងមានការឈឺក្បាល ឈឺចង្កេះ ឈឺក ឬក៏ឈឺក្រពះទៀត។ យើងនឹងលែងមានអារម្មណ៍ដឹងឈឺ នៅពេលដែលយើងដំដែកគោលខុស ចំមេដៃខ្លួនឯង។ ប៉ុន្តែ បើគ្មានការឈឺចាប់ទេ នោះយើងនឹងមិនដឹងថា យើងកំពុងតែបាក់ឆ្អឹង ឬដាច់សរសៃពួរសន្លាក់ឡើយ។ បើគ្មានការឈឺចាប់នៅក្នុងក្រពះទេ យើងនឹងមិនដឹងថា ដំបៅកំពុងតែស៊ីរូង នៅក្នុងក្រពះរបស់យើង។ យើងនឹងមិនដឹងថា ដុំសាច់កំពុងប្រែក្លាយជាមហារីក។ គ្មាននរណាចូលចិត្តការឈឺចាប់ទេ ប៉ុន្តែ ជាញឹកញាប់ ការឈឺចាប់កើតមានឡើង ដោយគោលបំណងល្អទេ។ ឧទាហរណ៍ ការឈឺចាប់គឺជាសញ្ញាដាស់តឿន ឲ្យយើងដឹងថា យើងកំពុងតែមានបញ្ហាអ្វីមួយហើយ។ ការឈឺចាប់ មិនមែនជាបញ្ហាពិតប្រាកដទេ តែបុព្វហេតុនៃការឈឺចាប់ទើបជាបញ្ហាពិតប្រាកដ។

ប៉ុន្តែ កាលពីដើមឡើយ ផែនដីមិនមានការឈឺចាប់ទេ។ កាលដែលព្រះជាម្ចាស់បានបង្កើតពិភពលោកមក អ្វីៗគ្រប់យ៉ាងមានភាពល្អឥតខ្ចោះ។ ឥតមានការឈឺចាប់។ ឥតមានការរងទុក្ខ។ ហើយក៏គ្មានការស្លាប់ដែរ។ គ្រប់យ៉ាងមានភាពល្អឥតខ្ចោះ ដោយមានព្រះជាម្ចាស់គ្រប់

គ្រង ហើយព្រះអង្គសព្វព្រះទ័យ នឹងមានទំនាក់ទំនងដ៏ជិតស្និទ និងប្រកបដោយសេចក្ដីស្រឡាញ់ ជាមួយអ័ដាម និងនាងអេវ៉ា ដែលជាបុរសស្ត្រីដំបូង ក្នុងពិភពលោកនេះ។

ប៉ុន្តែ ព្រះគម្ពីរប្រាប់យើងរាល់គ្នាថា អ័ដាម និងនាងអេវ៉ាបានបះបោរប្រឆាំង នឹងច្បាប់ដ៏ល្អរបស់ព្រះ ដោយការរឹងចចេស ដោយគិតថាខ្លួនចេះដឹងគ្រប់យ៉ាង។ ពួកគេមិនបានស្ដាប់បង្គាប់ទ្រង់ទេ។ ពួកគេចង់ឲ្យព្រះជាម្ចាស់ឈប់គ្រប់គ្រងជីវិតពួកគេ ហើយចង់សោយរាជលើជីវិតខ្លួនឯង។ ព្រះគម្ពីរហៅការបះបោរទាស់នឹងព្រះជាម្ចាស់ថា "បាប"។ ព្រោះតែអំពើបាប ពិភពលោកដ៏ស្រស់ត្រកាល និងទំនាក់ទំនងដ៏ឥតខ្ចោះរបស់មនុស្សជាមួយព្រះ ត្រូវខូចបង់។ គួរឲ្យស្ដាយ អំពើបាបនេះបានបន្តរហូតដល់ពេលបច្ចុប្បន្ន ហើយយើងរាល់គ្នាក៏បន្តរស់នៅ ជាមួយផលវិបាក នៃការបះបោរនោះ ដែលមានដូចជាការឈឺចាប់ ការរងទុក្ខ និងការស្លាប់។

ព្រោះតែអំពើបាប ពិភពលោកដ៏ស្រស់ត្រកាល និងទំនាក់ទំនងដ៏ឥតខ្ចោះរបស់មនុស្សជាមួយព្រះ ត្រូវខូចបង់។

ទុក្ខលំបាកទាំងអស់នេះ គឺបណ្ដាលមកពីការមិនស្ដាប់បង្គាប់របស់មនុស្សជាតិ ដែលរាប់បញ្ចូលទាំងអ័ដាម និងនាងអេវ៉ា ហើយនិងយើងរាល់គ្នា។ ព្រះទ្រង់មិនបានបង្កបញ្ហាទាំងនេះទេ ប៉ុន្តែ ដោយសេចក្ដីមេត្តាករុណារបស់ទ្រង់ នោះទ្រង់ប្រើប្រាស់ការរងទុក្ខរបស់យើងរាល់គ្នា ដើម្បីបង្រៀនយើងរាល់គ្នា ឲ្យស្គាល់ព្រះអង្គ។ លោក ស៊ី អែស លូអ៊ីស(C.S. Lewis) ធ្លាប់មានប្រសាសន៍ថា "ព្រះជាម្ចាស់ខ្សឹបដាក់យើងក្នុងភាពរីករាយរបស់យើង រួចទ្រង់មានបន្ទូលមកយើង ក្នុងបញ្ញាចិត្ត ឬសតិសម្បជញ្ញៈរបស់យើង តែទ្រង់ស្រែកមកកាន់យើង ក្នុងការឈឺចាប់របស់យើង ហើយទ្រង់ស្រែកដាក់មេក្រូរបស់ទ្រង់ ដើម្បីពញ្ញាក់លោកិយដែលមានត្រចៀកថ្លង់ ឲ្យភ្ញាក់ខ្លួនឡើង"។ ដូច្នេះ ការឈឺចាប់បានរំឭកយើងរាល់គ្នា ឲ្យពិចារណាអំពីបញ្ហាធំជាងនេះ ដែលកំពុងបំផ្លាញភពផែនដីរបស់យើង។ ការបាត់បង់ ការឈឺចាប់ផ្លូវចិត្ត និង

អារម្មណ៍ សង្គ្រាម គ្រោះទុរ្ភិក្ស ហើយនិងជំងឺ សុទ្ធតែបង្ហាញថា លោកិយសព្វថ្ងៃ មិនដូចជាអ្វី ដែលព្រះទ្រង់បង្កើតឡើងពីដំបូងនោះឡើយ។

យើងហាក់ដូចជាជឿកជាក់ថា យើងមានសិទ្ធិរស់នៅ ដោយមានសុខភាពល្អ និងរស់នៅ តាមសេចក្តីប្រាថ្នារបស់យើង។ ប៉ុន្តែ នៅពេលដែលយើងជួបប្រទះការឈឺចាប់ យើងងាយនឹងធ្លាក់ទៅក្នុងការល្បួង ឲ្យនិយាយថា "វាមិនសមសោះ"។ មនុស្សជាច្រើនបានតាំងចិត្តបដិសេធ ដោយបើកចំហថា ព្រះជាម្ចាស់មិនពិតជាមានមែនទេ ហើយអ្នកខ្លះទៀតបានបដិសេធទ្រង់ ដោយរស់នៅតាមចិត្ត ដែលហាក់ដូចជាគិតថា ព្រះពិតជាមិនមានមែន។ ប៉ុន្តែ អារម្មណ៍ដែលគិតថា ខ្លួនមិនសមនឹងជួបទុក្ខលំបាកទាំងនោះ ហាក់ដូចជាកំពុងទទួលស្គាល់ថា ព្រះពិតជាមានមែន។ ទោះជាយ៉ាងណាក៏ដោយ មនុស្សលោកបានប្រើមធ្យោបាយជាច្រើន ដើម្បីប្រកាស់ថា ពួកគេចង់បានពិភពលោកមួយដែលឥតមានព្រះ។ ដូច្នេះ ព្រះទ្រង់ក៏បានប្រទាន តាមអ្វីដែលយើងចង់បានមែន គឺពិភពលោកមួយ ដែលឥតមានច្បាប់ដ៏ល្អឥតខ្ចោះរបស់ទ្រង់។ ពិភពលោកនៃការឈឺចាប់។

ម្យ៉ាងវិញទៀត ព្រះគម្ពីរប្រាប់យើងថា ព្រះទ្រង់នៅតែយកព្រះទ័យទុកដាក់ ចំពោះទុក្ខលំបាករបស់យើង។ ការនេះបានបង្ហាញថា ព្រះទ្រង់នៅតែមានសេចក្តីស្រឡាញ់ យ៉ាងជ្រាលជ្រៅ ចំពោះយើង ទោះយើងហាក់ដូចជា បានតាំងចិត្តនឹងប្រព្រឹត្តតាមតែអំពើចិត្តរបស់យើង ហើយមិនចង់អើពើនឹងទ្រង់ក៏ដោយ។

ដូច្នេះ តើយើងរំពឹងចង់បាន ពិភពលោកដែលពេញដោយការឈឺចាប់នេះឬ?

## ពិភពលោកដែលគ្មានការឈឺចាប់

មនុស្សយើងនៅតែប្រព្រឹត្តខុស តាមអ័ដាម និងអេវ៉ា ដោយបដិសេធមិនព្រមឲ្យព្រះជាម្ចាស់គ្រប់គ្រងជីវិត ដោយមិនស្តាប់បង្គាប់ទ្រង់។ យើងទាំងអស់គ្នា សុទ្ធតែមានទោស ដោយសារការមិនស្តាប់បង្គាប់នេះ។ ប៉ុន្តែ ព្រះទ្រង់សព្វព្រះទ័យឲ្យយើងរកឃើញដំណោះ

ស្រាយពិតប្រាកដ សម្រាប់ទុក្ខលំបាករបស់យើង។ ទ្រង់សព្វព្រះទ័យឲ្យយើងទាំងអស់គ្នា ទុកចិត្តលើផែនការរបស់ទ្រង់។ ព្រះទ្រង់បានសន្យាថានឹងដោះស្រាយបញ្ហានៃអំពើបាប និងការបែកបាក់ទំនាក់ទំនងរវាងយើងនឹងទ្រង់ ហើយដំណោះស្រាយរបស់ទ្រង់ ផ្តល់មកនូវសេចក្តីសង្ឃឹមតែមួយគត់ នៅក្នុងពិភពលោកពេញដោយការរងទុក្ខនេះ។

ដូច្នេះ សេចក្តីសង្ឃឹមនោះមានលក្ខណៈដូចម្តេចខ្លះ? កណ្ឌចុងក្រោយនៃព្រះគម្ពីរបរិសុទ្ធ បានបើកសម្តែងឲ្យឃើញព្រឹត្តិការណ៍ ដែលនឹងត្រូវកើតឡើងនៅពេលខាងមុខ។ បទគម្ពីរនោះបានប្រាប់យើង អំពីពេលដែលព្រះទ្រង់នឹងស្តារគ្រប់ការទាំងអស់ ឲ្យបានត្រឡប់ដូចដើមវិញ តាមបំណងព្រះទ័យដើមរបស់ទ្រង់។ គម្ពីរ វិវរណៈ ២១:៣-៤ ប្រាប់យើងថា . . .

> *រោងឧបោសថរបស់ព្រះ បាននៅជាមួយនឹងមនុស្ស! ទ្រង់នឹងគង់នៅជាមួយនឹងគេ គេនឹងធ្វើជារាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ក៏នឹងធ្វើជាព្រះដល់គេ។ ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ និងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មាន បានកន្លងបាត់ទៅហើយ។*

តើនោះមិនមែនជាអ្វីដែលយើងស្រមៃទេឬ? យើងគ្រប់គ្នាសុទ្ធតែប្រាថ្នាចង់បាន ពិភពលោកមួយដែលល្អឥតខ្ចោះ ជាកន្លែងដែលគ្មានការឈឺចាប់ ឬការរងទុក្ខអ្វីទាំងអស់។ ប៉ុន្តែ ទោះបីជាមនុស្សយើងប្រឹងប្រែងយ៉ាងណាក៏ដោយ ទោះជាតាមផ្លូវវិទ្យាសាស្ត្រ ឬនយោបាយ ឬក៏ផ្លូវបរិស្ថាននិយម ឬតាមអ្វីផ្សេងក្តី ក៏គ្មានអ្វីអាចបង្កើតពិភពលោកមួយឲ្យដ៏ល្អឥតខ្ចោះបានដែរ។ មានតែព្រះមួយអង្គគត់ ដែលអាចធ្វើការនេះបាន។ ក្នុងពេលអនាគត នៅពេលដែលព្រះទ្រង់ធ្វើឲ្យពិភពលោកល្អឥតខ្ចោះឡើងវិញ ព្រះអង្គនឹងធ្វើជាចំណុចកណ្តាលនៃអ្វីៗគ្រប់យ៉ាង ហើយទ្រង់នឹងស្តារទំនាក់ទំនងដែលយើងមានជាមួយទ្រង់ឡើងវិញ។

នោះគឺជាសណ្ឋានដើមនៃជីវិត ដែលទ្រង់បានតម្រូវទុកតាំងពីដំបូងមក ហើយអស់អ្នកដែលព្រះទ្រង់បានសង្គ្រោះឲ្យរួចពីអំពើបាប កំពុងតែទន្ទឹងចាំជីវិតដ៏ល្អឥតខ្ចោះនោះឯង។

## តើយើងអាចទទួលការសង្គ្រោះ ដោយរបៀបណា?

ពិភពលោកបានប្រែជារញ៉េរញ៉ៃ ព្រោះតែអំពើបាបរបស់មនុស្ស។ យើងរាល់គ្នាមិនមានអំណាចអ្វី ដើម្បីកែប្រែវាឲ្យល្អដូចដើមបានឡើយ។ ហេតុដូច្នេះហើយ ទើបព្រះទ្រង់ចាត់អង្គបុគ្គលមួយមក ឲ្យជួសជុលការទាំងអស់ឡើងវិញ។ អង្គបុគ្គលនោះ ជាព្រះរាជបុត្រារបស់ទ្រង់ ដែលមានព្រះនាមថា ព្រះយេស៊ូវគ្រីស្ទ។ ដើម្បីទទួលការសង្គ្រោះនោះ យើងត្រូវទទួលជឿព្រះយេស៊ូវគ្រីស្ទ។ ព្រះគម្ពីរចែងថា:

> *ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ ដោយសារទ្រង់វិញ។ (យ៉ូហាន ៣:១៦-១៧)។*

ព្រះគម្ពីរបានចែងថា នៅពេលដែលយើងទទួលជឿព្រះយេស៊ូវគ្រីស្ទ យើងនឹងទទួលបានជីវិតអស់កល្បជានិច្ច តាមព្រះបន្ទូលសន្យារបស់ទ្រង់។ មានន័យថា ពេលដែលយើងស្លាប់ទៅ យើងនឹងទៅរស់នៅជាមួយព្រះជាម្ចាស់ ហើយយើងនឹងរួចផុតពីការឈឺចាប់ និងទុក្ខលំបាកគ្រប់យ៉ាង។ ប៉ុន្តែ បើយើងស្មោះត្រង់នឹងខ្លួនឯង នោះយើងនឹងទទួលស្គាល់ថា យើងបានប្រព្រឹត្តអំពើបាបជារៀងរាល់ពេល នៅក្នុងការគិត ហើយការធ្វើ និងការនិយាយស្តី។ ដូច្នេះ តើយើងរាល់គ្នាអាច

> **ព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង(រ៉ូម ៥:៦-៨)។**

ធ្វើល្អឲ្យបានគ្រប់គ្រាន់ ល្មមនឹងឲ្យព្រះទ្រង់ទទួលយើងចូលនគរស្ថានសួគ៌ដែរឬទេ?

> *ដ្បិតកាលយើងនៅខ្សោយនៅឡើយ លុះដល់កំណត់ហើយ នោះព្រះគ្រីស្ទទ្រង់បានសុគតជំនួសមនុស្សទមិលល្មើស . . . ព្រះទ្រង់សំដែងសេចក្ដីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង(រ៉ូម ៥:៦-៨)។*

ដោយសារសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ នោះទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់តែមួយ គឺព្រះយេស៊ូវគ្រីស្ទ ឲ្យយាងមកសុគតជំនួសយើងរាល់គ្នា ដែលតាមពិត គឺយើងទេ ដែលសមនឹងទទួលការស្លាប់នោះ។ ទ្រង់បានសុគត "ចំពេល ដែលបានកំណត់"។ បើគ្មានទ្រង់ទេ យើងច្បាស់ជាគ្មានអំណាចដោះស្រាយបញ្ហា នៃអំពើបាបក្នុងលោកិយនេះបានឡើយ។

ព្រះយេស៊ូវមិនដូចយើងរាល់គ្នាទេ។ ទ្រង់មិនដែលធ្វើអំពើបាបសោះ។ មានតែទ្រង់ទេដែលមិនដែលបដិសេធព្រះជាម្ចាស់ទាល់តែសោះ។ ប៉ុន្តែ ទ្រង់ស៊ូរងទ្រាំការឈឺចាប់ និងទុក្ខវេទនាក្រៃលែង។ ទ្រង់ទទួលទោសនោះ ជំនួសយើងរាល់គ្នា។ ទ្រង់ត្រូវគេបដិសេធ ហើយទ្រង់ទទួលរងការវាយដំ ការជេរប្រមាថ និងត្រូវគេព្យួរនៅលើឈើឆ្កាងរហូតអស់ព្រះជន្ម ហើយត្រូវចាក់នឹងលំពែងទៀត ទ្រង់ទទួលរងទាំងអស់នេះដោយសារអំពើបាបរបស់យើងរាល់គ្នា។ ទ្រង់ស្ម័គ្រព្រះទ័យសុគតនៅលើឈើឆ្កាង ដើម្បីទទួលទោស នៃការមិនស្ដាប់បង្គាប់របស់យើងរាល់គ្នា ដើម្បីកុំឲ្យយើងទទួលទោសនោះ។ គឺដូចមានសេចក្ដីចែងថា "ព្រះគ្រីស្ទទ្រង់បានយាងមក ចំពេលកំណត់ ព្រមទាំងបានសុគតជួសយើង ដែលជាមនុស្សមានបាប"។

នោះជាការបង់ថ្លៃដ៏ច្រើនក្រៃលែង ដើម្បីលោះយើងឲ្យរួចពីទោសនៃអំពើបាប! ព្រះយេស៊ូវគ្រីស្ទបានលះបង់ព្រះជន្មទ្រង់ ជំនួសមនុស្សដូចយើងរាល់គ្នា។ ប៉ុន្តែ រឿងនេះមិនទាន់ចប់ត្រឹមនេះឡើយ។ ព្រះគម្ពីរបានចែងថា ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ។ ទ្រង់បាន

យកឈ្នះសេចក្តីស្លាប់ សម្រាប់អស់អ្នកណា ដែលទទួលជឿទ្រង់។

ហេតុនេះហើយ យើងត្រូវទទួលជឿព្រះយេស៊ូវ។ ពេលណាយើងទទួលជឿទ្រង់ គឺមានន័យថា យើងអនុញ្ញាតឲ្យទ្រង់គ្រប់គ្រងជីវិតយើង ហើយទ្រង់នឹងដកនាំងនៃទំនាក់ទំនង ដែលកើតចេញពីអំពើបាបរបស់យើង បានសេចក្តីថា ទ្រង់នឹងផ្សះផ្សាឲ្យយើងជានឹងព្រះ ហើយមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយទ្រង់។ យើងនឹងមានអនាគតដ៏អស្ចារ្យ ដូចដែលយើងបានអានក្នុងទំព័រមុន។ លែងមានទឹកភ្នែក។ លែងមានការស្លាប់។ លែងមានទុក្ខសោក។ លែងមានការទួញយំ។ លែងមានការឈឺចាប់។

> ព្រះគម្ពីរបានចែងថា ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ។ ទ្រង់បានយកឈ្នះសេចក្តីស្លាប់ សម្រាប់អស់អ្នកណា ដែលទទួលជឿទ្រង់។

សូមយើងគិតឡើងវិញ អំពីដើមដំបូងនៃជីវិតមនុស្ស នៅលើផែនដីនេះ។ ពិភពលោកនេះ អាចធ្វើជាកន្លែងដែលមានសុភមង្គលដ៏អស្ចារ្យ តែវាបានប្រឡាក់ទៅដោយទុក្ខវេទនា និងការឈឺចាប់ គ្រប់ច្រកល្ហកទាំងអស់។ យើងប្រាថ្នាចង់គេចចេញពីទុក្ខព្រួយទាំងអស់ ហើយក៏បានព្យាយាមប្រើគ្រប់មធ្យោបាយដើម្បីគេចឲ្យផុត។ ប៉ុន្តែ មានតែសេចក្តីសន្យា និងកិច្ចការដែលព្រះជាម្ចាស់បានធ្វើប៉ុណ្ណោះ ដែលអាចជួយឲ្យយើងគេចផុត យ៉ាងជាក់ច្បាស់។

ព្រះចេស្តា និងសេចក្តីសន្យារបស់ព្រះជាម្ចាស់ នឹងកែប្រែអ្វីៗគ្រប់យ៉ាង ដែលយើងបានស្គាល់។ យើងដឹងថា យើងមានរដូវកាលនៃការឈឺចាប់ ក្នុងជីវិតនេះ ហើយថ្ងៃណាមួយ យើងនឹងត្រូវស្លាប់។ នេះជាការពិតដែលមិនអាចប្រកែកបាន។ ប៉ុន្តែ ព្រះទ្រង់សន្យាថា យើងនឹងជួបរឿងដែលខុសពីនេះ គឺសន្យាថា នឹងប្រទាននូវជីវិត ដែលមានសេចក្តីសុខសាន្ត ក្តីអំណរ និងសុភមង្គល ជាមួយទ្រង់ ជារៀងរហូត!

តើយើងអាចធ្វើអ្វីបាន ដើម្បីឲ្យបានរស់នៅក្នុងពិភពលោកដែលគ្មានសេចក្តីទុក្ខ? យើងមិនអាចធ្វើអ្វីបានទេ។ ព្រះជាម្ចាស់ជាអ្នកផ្តួចផ្តើមទាំងស្រុង។ ហេតុដូច្នេះហើយ យើងមានជម្រើសតែមួយគត់ គឺ

ត្រូវទទួលយកដំណោះស្រាយរបស់ទ្រង់ ដោយការជឿជាក់លើទ្រង់។

ខណៈពេលដែលអ្នកកំពុងអានសៀវភៅនេះ តើអ្នកបានអនុញ្ញាតឲ្យព្រះយេស៊ូវ ធ្វើជាចំណុចកណ្តាលនៃជីវិតរបស់អ្នកហើយឬនៅ? អ្នកក៏ប្រហែលជា មិនដែលគិតថា អ្នកអាចទៅរស់នៅក្នុងពិភពលោកដែលគ្មានសេចក្តីទុក្ខនោះឡើយ។ អ្នកប្រហែលជាមានការប៉ះពាល់ចិត្ត ពេលដែលព្រះគម្ពីរបានថែង អំពីប្រភពនៃសេចក្តីទុក្ខ ដែលបានកើតមានក្នុងពិភពលោកនេះ។ អ្នកប្រហែលជាចង់ចាប់ផ្តើមទទួលព្រះយេស៊ូវ ធ្វើជាចំណុចកណ្តាលនៃជីវិតរបស់អ្នក នៅថ្ងៃនេះ។

> ព្រះទ្រង់សន្យាថា យើងនឹងជួបរឿងដែលខុសពីនេះ គឺសន្យាថា នឹងប្រទាននូវជីវិត ដែលមានសេចក្តីសុខសាន្ត ក្តីអំណរ និងសុភមង្គល ជាមួយទ្រង់ ជារៀងរហូត!

បើដូច្នោះមែន សូមអានលំនាំនៃសេចក្តីអធិស្ឋានខាងក្រោមនេះ ដែលនឹងជួយឲ្យអ្នកទទួលព្រះយេស៊ូវ។ ប្រសិនបើអ្នកអធិស្ឋានតាមលំនាំខាងក្រោមនេះ យ៉ាងអស់ពីចិត្ត អ្នកអាចចាប់ផ្តើមជីវិត ថ្មី។ គឺចាប់ផ្តើមជីវិតថ្មីជាគ្រីស្ទបរិស័ទ ដែលជាការរស់នៅដ៏ត្រឹមត្រូវ ក្នុងពេលបច្ចុប្បន្ននេះ ហើយជាវិធីតែមួយ ដើម្បីឲ្យយើងអាចរស់នៅក្នុងពិភពលោកដែលព្រះជាម្ចាស់បានសន្យាប្រទាន ជាទីកន្លែងដែលគ្មានទឹកភ្នែក គ្មានការស្លាប់ គ្មានសេចក្តីសោកសង្រេង គ្មានការវេទនា និងការឈឺចាប់ឡើយ។

ការអធិស្ឋាននេះគឺជាការសារភាពថា តាំងពីដើមមក យើងបានបដិសេធព្រះជាម្ចាស់។ បន្ទាប់មក យើងអរព្រះគុណទ្រង់ សម្រាប់សេចក្តីស្រឡាញ់ ដែលទ្រង់បានបង្ហាញដល់យើងរាល់គ្នា នៅក្នុងព្រះយេស៊ូវ ហើយទូលសូមឲ្យទ្រង់ជួយយើង ឲ្យទុកចិត្តព្រះអង្គ ជារៀងរាល់ថ្ងៃ។ ការអធិស្ឋាននេះគឺងាយស្រួលទេ តែវាជាការសម្រេចចិត្តដ៏ធំបំផុត នៅក្នុងជីវិតរបស់អ្នក។

## លំនាំនៃការអធិស្ឋាន

*ព្រះអម្ចាស់យេស៊ូវអើយ ទូលបង្គំត្រូវការព្រះអង្គ។ អរព្រះគុណព្រះអង្គ ដែលបានស្រឡាញ់ទូលបង្គំយ៉ាងខ្លាំង បានជាទ្រង់យាងមកសុគតនៅលើឈើឆ្កាង ដើម្បីលោះទូលបង្គំឲ្យរួចពីបាប។ ទូលបង្គំសូមបើកទ្វារជីវិតទូលបង្គំ ទទួលព្រះអង្គ ធ្វើជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់ទូលបង្គំ។អរព្រះគុណព្រះអង្គ ដែលបានអត់ទោសបាប ឲ្យទូលបង្គំ។ ហើយប្រទានជីវិតអស់កល្បជានិច្ចដល់ទូលបង្គំ។ សូមយាងមកសោយរាជ្យ លើបល្ល័ង្កជីវិតទូលបង្គំ។ សូមកែផ្នែទូលបង្គំ ទៅជាមនុស្ស ដែលព្រះអង្គសព្វព្រះទ័យ។ អាម៉ែន។*

ពេលដែលយើងទទួលស្គាល់អំពើបាបរបស់យើង ដោយចិត្តស្មោះត្រង់ និងទទួលការសង្គ្រោះរបស់ព្រះយេស៊ូវ ដោយជឿលើទ្រង់ យើងនឹងមានទំនាក់ទំនងដ៏ត្រឹមត្រូវ ជាមួយព្រះជាម្ចាស់ ដែលនេះជាបំណងព្រះទ័យទ្រង់ តាំងពីដើមមក។ ហើយនោះជាឯកសិទ្ធិដ៏វិសេសបំផុត!

ជីវិតជាគ្រីស្ទបរិស័ទ គឺជាការឆ្លុះបញ្ចាំងដ៏តូចមួយ អំពីពិភពលោកថ្មី ដែលព្រះទ្រង់បានរៀបចំទុក នៅពេលអនាគត។ គ្រីស្ទបរិស័ទអាចទុកចិត្តលើព្រះបន្ទូលសន្យា អំពីពេលអនាគត ដែលយើងនឹងបានរស់នៅជាមួយព្រះជាម្ចាស់អស់កល្បជានិច្ច ដូចមានចែង ក្នុងព្រះគម្ពីរវិវរណៈ ២១:៣-៤។ សម្រាប់អស់អ្នកណា ដែលទុកចិត្តព្រះជាម្ចាស់ រាល់ការឈឺចាប់ និងការរងទុក្ខ ក្នុងជីវិតនេះ គ្រាន់តែជារឿងបណ្តោះអាសន្នប៉ុណ្ណោះ បើធៀបនឹងភាពអស់កល្បជានិច្ច ដែលនៅក្នុងពេលខាងមុខ។ ថ្ងៃណាមួយ យើងនឹងលែងមានការឈឺចាប់ និងការរងទុក្ខ ហើយយើងនឹងរស់នៅ ក្នុងពិភពលោក ដែលព្រះស្តារឡើងវិញយ៉ាងល្អឥតខ្ចោះ។

ការរស់នៅជាគ្រីស្ទបរិស័ទ មិនមែនមានន័យថា យើងនឹងមិនជួបការឈឺចាប់ និងការរងទុក្ខ នៅពេលបច្ចុប្បន្ននោះទេ ប៉ុន្តែ ព្រះទ្រង់

នឹងប្រទានកម្លាំង ឲ្យយើងអាចប្រឈមមុខចំពោះបញ្ហាគ្រប់យ៉ាង។ ជីវិតជាគ្រីស្ទបរិស័ទ នឹងមិនងាយស្រួលរហូតឡើយ ប៉ុន្តែ យើងអាចទូលសូមជំនួយ ពីព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ តាមរយៈការអធិស្ឋាន។ យើងអាចរស់នៅថ្វាយទ្រង់ នៅពេលបច្ចុប្បន្ននេះ ហើយទន្ទឹងរង់ចាំថ្ងៃដែលព្រះទ្រង់ប្រទានពិភពលោកថ្មី តាមព្រះបន្ទូលសន្យាទ្រង់។ ពិភពលោកថ្មីនោះមិនមានការស្លាប់ ការសោកសង្រេង ការយំសោក និងការឈឺចាប់ឡើយ។

ប្រសិនបើអ្នកចង់ស្វែងយល់បន្ថែមទៀត អំពីព្រះយេស៊ូវ អ្នកអាចទំនាក់ទំនងព្រះវិហារគ្រីស្ទបរិស័ទ ក្នុងតំបន់របស់អ្នក។ នៅទីនោះនឹងមានមនុស្សដែលអាចជួយឆ្លើយសំណួរដែលអ្នកមាន។ យើងខ្ញុំនៅឯអង្គការនំម៉ាណាប្រចាំថ្ងៃ ក៏រង់ចាំស្វាគមន៍លោកអ្នកជានិច្ច។

បើអ្នកចង់អានសៀវភៅផ្សេងទៀត ដែលទាក់ទងនឹងព្រះគម្ពីរ សូមចូលទៅកាន់វេបសាយរបស់យើងខ្ញុំ ដែលមានអាស័យដ្ឋាន www.khmer-odb.org/ds/។

ប្រែសម្រួលជាភាសាខ្មែរ ដោយ លោក លី ប៊ុនថា

ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលអត្ថបទដោយ : លោក ឯក សត្យា

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។

រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2018 ODB Ministries (website: www.odb.org)

ចេញផ្សាយដោយ : ODB Cambodia (email: cambodia@odb.org, Tell: 087 233 907, website: http://khmer-odb.org, Facebook page : https://www.facebook.com/khmer.odb)